ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រដ្ឋបាលជលផល

# សៀវភៅមេរៀនស្តីពី
# សហគ្រប់គ្រងធនធានជលផល

## សៀវភៅទី៣ : ការពង្រឹងគណៈកម្មការសហគមន៍នេសាទ



ខែសីហា ឆ្នាំ២០១៨

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប

# សៀវភៅមេរៀនស្តីពីសហគ្រប់គ្រងធនធានជលផល

# សៀវភៅទី៣ : ការពង្រឹងគណៈកម្មការសហគមន៍នេសាទ

រៀបចំដោយ
វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប
រដ្ឋបាលជលផល

សេចក្តីថ្លែងអំណរគុណ
រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចងក្រងសៀវភៅមេរៀននេះ ក្រោមការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារពិភពលោក។

សៀវភៅមេរៀនទាំងនេះគឺជាសមិទ្ធិផលរបស់គម្រោងការគ្រប់គ្រងធនធានទឹកចម្រុះ ទន្លេមេគង្គ - ដំណាក់កាលទី ៣ (M-IWRMP-III) "ការគាំទ្រការគ្រប់គ្រងធនធានជលផលនៅភូមិភាគឦសាននៃប្រទេសកម្ពុជា" ដែលអនុវត្តដោយ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប។

**ចងក្រងដោយ**

រូបឹត៍ ផមរ៉យ អេរិក បារ៉ាន ទូច គឹមឆាន សូខន សាវុទ្ធ លី វុទ្ធី ទុយ សមរាំ ឈួន ឡា
សូ វត្ថថាវី ផា ស្រួយ ប៊ុន ប៉ាស៊ី ទូច ប៊ុនថង ឆេង ផែន និង អេង ជាសាន។

**ជំនួយការ**

ស៊ឹម ថាវរី អ៊ូ សារី ធៀង សីហា ភូ សុខ ទិត្យ ពុទ្ធារ័ត្ន ប៉ុស ចាន់ណារ៉ា
កែន ឡៃហ៊ាង ភាជន៍ ឧស្សាហ៍ ទឹម សណ្ដាន និងគូររូបដោយ ហេង សន្ធា។

សូមថ្លែងអំណរគុណដល់អ្នកជំនាញការ និងទីប្រឹក្សានៃធនាគារពិភពលោកដែលបានផ្ដល់នូវមតិ និងកែលម្អ។

**ISBN-13: 978-9924-9278-4-6**

**គុណកថាបង្អែក**

រដ្ឋបាលជលផល (២០១៨). សៀវភៅបណ្ដុះបណ្ដាលស្ដីពីការសហការគ្រប់គ្រងជលផល សៀវភៅទី៣៖ ការពង្រឹងគណៈកម្មការសហគមន៍នេសាទ។ រដ្ឋបាលជលផល និងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប រាជធានីភ្នំពេញ ប្រទេសកម្ពុជា ៣២ទំព័រ។

**អាសយដ្ឋានទំនាក់ទំនង**

រដ្ឋបាលជលផល

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប

អាគារលេខ ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា

គេហទំព័រ ifredi-cambodia.org

**© រដ្ឋបាលជលផល (២០១៨)**

រក្សាសិទ្ធិ។ ការបោះពុម្ពឡើងវិញទាំងស្រុង ឬផ្នែកណាមួយសម្រាប់គោលបំណងអប់រំ ឬមិនរកប្រាក់ចំណេញ ដោយមិនចាំបាច់សុំការអនុញ្ញាតពីម្ចាស់ដើម និងគ្រាន់តែថ្លែងអំណរគុណដល់ប្រភពដើមត្រូវបានអនុញ្ញាត។ រាល់ការបោះពុម្ព ការចម្លង ឬចែកចាយសម្រាប់ធ្វើពាណិជ្ជកម្មត្រូវសុំការអនុញ្ញាតពីរដ្ឋបាលជលផល។

គ្រប់មតិ និងគំនិតទាំងអស់ជាទស្សនៈរបស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងពីរដ្ឋបាលជលផល ដៃគូ ស្ថាប័នគាំទ្រគម្រោង និងការបោះពុម្ពសៀវភៅនេះ។

# មាតិកា


១. ភាពជាអ្នកដឹកនាំរបស់គណៈកម្មការសហគមន៍នេសាទ ........................................................ ១

២. ការគ្រប់គ្រងធនធានជលផលផ្តោតលើប្រព័ន្ធអេកូឡូស៊ី ..................................................... ២

៣. តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍នេសាទ ...................................... ៥

៤. គណៈកម្មការសហគមន៍នេសាទ និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ........................ ៧

៥. តួនាទីគណៈកម្មការសហគមន៍នេសាទ ក្នុងការធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........................................................................................................ ៨

៦. គណៈកម្មការសហគមន៍នេសាទ និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ .................... ៩

៦.១ ការធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........................................ ៩

៦.២ គណៈកម្មការសហគមន៍នេសាទណែនាំសមាជិកពីផ្នែកសំខាន់ៗនៃផែនការគ្រប់គ្រង...... ១១

៦.២.១ ទស្សនៈវិស័យរបស់សហគមន៍នេសាទ ............................................................ ១២

៦.២.២ កំណត់បញ្ហា និងការគំរាមកំហែង................................................................ ១៣

៦.២.៣ ការចាត់អាទិភាពបញ្ហា និងការគំរាមកំហែង .................................................. ១៥

៦.២.៤ ការកំណត់តម្រូវការ និងចាត់អាទិភាព............................................................ ១៦

៦.២.៥ ការកំណត់គោលដៅ និងគោលបំណង ............................................................ ១៧

៦.២.៦ ការកំណត់វិធានការគ្រប់គ្រង...................................................................... ១៨

៦.៣ បញ្ហាយេនឌ័រ និងជនជាតិដើមភាគតិច ក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ .. ២០

៧. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការគ្រប់គ្រង....................................................... ២១

៨. គណៈកម្មការសហគមន៍នេសាទ និងការគ្រប់គ្រងវិវាទ...................................................... ២២

៩. តួនាទីគណៈកម្មការសហគមន៍នេសាទចំពោះការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់ ......... ២៤

១០. តួនាទីនៃគណៈកម្មការសហគមន៍នេសាទក្នុងការកៀរគរថវិកា ......................................... ២៦

១១. តួនាទីគណៈកម្មការសហគមន៍នេសាទក្នុងការរៀបចំផែនការសកម្មភាព និងរបាយការណ៍ . ២៨

១១.១ ការរៀបចំផែនការសកម្មភាព........................................................................ ២៨
១១.២ ការធ្វើរបាយការណ៍ ............................................................................................. ២៩
១២. កិច្ចសហការជាមួយខណ្ឌរដ្ឋបាលជលផល .............................................................. ៣០
១៣. ការបញ្ចូលលទ្ធផលផែនការគ្រប់គ្រងទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់........................ ៣២

## ១. ភាពជាអ្នកដឹកនាំរបស់គណៈកម្មការសហគមន៍នេសាទ

គណៈកម្មការសហគមន៍នេសាទ គឺជាក្រុមមនុស្សដែលមានសមាជិកបោះឆ្នោតឱ្យដើម្បីដឹកនាំសហគមន៍នេសាទ។ អ្នកដឹកនាំគួរផ្ដល់នូវការទូន្មាន និងលើកទឹកចិត្តដល់សមាជិក និងបំផុសសមាជិកឱ្យយល់ដឹង និងចូលរួមអនុវត្តឱ្យបានសម្រេចបាននូវទស្សនៈវិស័យ ធ្វើការជាមួយគ្នា និងបង្កើននូវប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានប្រកបដោយគុណធម៌ និងសីលធម៌សង្គម។

ភារកិច្ចរបស់អ្នកដឹកនាំ គឺនាំមនុស្សមួយក្រុមឱ្យសម្រេចគោលបំណងដែលគេចង់បាន។



### គន្លឹះសម្រាប់អ្នកសម្របសម្រួល

អ្នកដឹកនាំ គឺជាបុគ្គលដែលជឿថាធ្វើការដើម្បីប្រយោជន៍មនុស្សគ្រប់គ្នា។ អ្នកដឹកនាំត្រូវការគ្រប់គ្រង លើកទឹកចិត្ត និងទូន្មាន ដើម្បីឱ្យអង្គភាពមានដំណើរការល្អ។

អ្នកដឹកនាំល្អ៖

- ជាអ្នកលើកទឹកចិត្ត យកចិត្តទុកដាក់ មានអាកប្បកិរិយាវិជ្ជមានចំពោះមនុស្សជុំវិញខ្លួន
- ស្ដាប់ ប្រាស្រ័យទាក់ទង រួបរួម និងមានគុណធម៌រួម (មានឆន្ទៈចែករំលែកដល់ក្រុម)
- ប្រមូលផ្ដុំភាពខ្លាំង និងទេពកោសល្យរបស់ក្រុមទាំងមូល
- ផ្សព្វផ្សាយគុណតម្លៃរបស់អង្គភាព និងដឹកនាំជាគំរូ
- មានឆន្ទៈ និងការទទួលខុសត្រូវខ្ពស់។

## ២. ការគ្រប់គ្រងធនធានជលផលផ្ដោតលើប្រព័ន្ធអេកូឡូស៊ី

ការគ្រប់គ្រងធនធានជលផល ប្រសិនបើមិនបានគិតគូរដល់បរិស្ថាននោះទេគឺនាំឱ្យការគ្រប់គ្រងគ្មានប្រសិទ្ធភាពឡើយ។ ដូចនេះទើបយើងស្វែងរកគោលការណ៍នៃការគ្រប់គ្រងដែលមានលក្ខណៈសមស្រប ពោលគឺការគ្រប់គ្រងដោយផ្ដោតលើប្រព័ន្ធអេកូឡូស៊ី។ រដ្ឋបាលជលផល បានឯកភាពចំពោះគោលការណ៍នេះ ហើយការអនុវត្តវិធីសាស្ត្រនេះ ក្នុងការគ្រប់គ្រងសហគមន៍នេសាទ គឺជាការងារមួយល្អប្រសើរ។

ការគ្រប់គ្រងដោយផ្ដោតលើប្រព័ន្ធអេកូឡូស៊ីគឺជាការគ្រប់គ្រងគិតគូរដល់ការធ្វើឱ្យមានតុល្យភាពរវាងកត្តាបរិស្ថាន សង្គម(សុខុមាលភាព) និងអភិបាលកិច្ច។

- បរិស្ថានល្អ៖ មានពូជត្រីច្រើនប្រភេទ ផលត្រីសម្បូរ មិនធ្វើឱ្យបាត់បង់ជម្រកត្រី និងទឹកមានគុណភាព
- សង្គម(សុខុមាលភាព)៖ ប្រជាពលរដ្ឋមានស្តង់ដាររស់នៅល្អ (ប្រាក់ចំណូលសមរម្យ) សុវត្ថិភាពស្បៀង ទំនាក់ទំនងសង្គមមានភាពប្រសើរឡើង និងធានាសុវត្ថិភាព
- អភិបាលកិច្ចល្អ៖ សំដៅដល់ចូលរួម សិទ្ធិជាផ្លូវការ សមធម៌ យន្តការរៀបចំផែនការ និងការអនុវត្ត ការគោរព និងពង្រឹងការអនុវត្តច្បាប់។



## គន្លឹះសម្រាប់អ្នកសម្របសម្រួល

ត្រីរស់នៅបានអាស្រ័យនឹងប្រព័ន្ធអេកូឡូស៊ីរួមមាន៖ កត្តាទឹក ជម្រកពងកូន និងមនុស្ស។ ការគ្រប់គ្រងធនធានជលផលដោយមិនបានគ្រប់គ្រងបរិស្ថាននាំឱ្យគ្មានប្រសិទ្ធភាព និងគ្មាននិរន្តរភាព។ នៅពេលខ្លះ ការគ្រប់គ្រងធនធានជលផលខកខានក្នុងការការពារសហគមន៍ក្រីក្រ ដែលតែងតែទាញផលប្រយោជន៍ពីធនធានធម្មជាតិ ក៏ដូចជាផលប្រយោជន៍សេដ្ឋកិច្ចសង្គម។ ដើម្បីឆ្លើយតបនឹងតម្រូវការនេះ "ការគ្រប់គ្រងធនធានជលផលតាមបែបប្រព័ន្ធអេកូឡូស៊ី" ត្រូវបានបង្កើតឡើង។ វិធីសាស្ត្រនេះមានលក្ខណៈចូលរួម និងចម្រុះ ដែលពិចារណាផ្តោតលើ៖ ១)ធនធានជលផល ២)ធាតុសំខាន់ៗនៃប្រព័ន្ធអេកូឡូស៊ី និង៣)ផលប្រយោជន៍សេដ្ឋកិច្ចសង្គមដែលទទួលបាន។

ប្រព័ន្ធអេកូឡូស៊ីកំណត់នូវតុល្យភាពរវាង ១)បរិស្ថានល្អ ២)សុខុមាលភាពប្រជាពលរដ្ឋ និង ៣)អភិបាលកិច្ចល្អសម្រាប់មនុស្សជំនាន់ក្រោយ។

ការគ្រប់គ្រងធនធានជលផល តាមបែបប្រព័ន្ធអេកូឡូស៊ី ផ្តោតលើទិដ្ឋភាពធំដែលទទួលស្គាល់ ថាធនធានជលផល ជាចំណែកមួយនៃប្រព័ន្ធអេកូឡូស៊ី ដែលត្រីរស់នៅបានក្នុងទឹក និងមនុស្សក៏ទទួលបានផលប្រយោជន៍ពីការនេសាទ លក់ដូរ ព្រមទាំងបរិភោគផងដែរ។

ប្រទេសកម្ពុជាជាប្រទេសហត្ថលេខីនៃលិខិតបទដ្ឋានចំនួនពីរនៃអង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ លើវិស័យជលផល៖

- ក្រមសីលធម៌នៃការទទួលខុសត្រូវក្នុងវិស័យជលផល
- គោលការណ៍ណែនាំស្តីពីវិស័យជលផលខ្នាតតូច

លិខិតបទដ្ឋានទាំងពីរ ត្រូវបានរាប់បញ្ចូលក្នុងការគ្រប់គ្រងធនធានជលផលតាមបែបប្រព័ន្ធអេកូឡូស៊ី។

# គោលការណ៍ទាំង៧ នៃការគ្រប់គ្រងធនធានជលផលផ្តោតលើប្រព័ន្ធអេកូឡូស៊ី

**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

ការគ្រប់គ្រងធនធានជលផលផ្តោតលើប្រព័ន្ធអេកូឡូស៊ី ឈរលើគោលការណ៍ចំនួន ៧ រួមមាន៖

- អភិបាលកិច្ចល្អ៖ ការដឹកនាំ និងគ្រប់គ្រងប្រកបដោយគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព ភាពសក្តិសិទ្ធ និងនីតិរដ្ឋ
- ខ្នាតតូច៖ ដែននេសាទ ពេលវេលា និងឧបករណ៍នេសាទ...
- បង្កើនការចូលរួម៖ ប្រជានេសាទចូលរួមសម្រេចចិត្ត
- គោលដៅច្រើន៖ ធ្វើឱ្យមានតុល្យភាពរវាងតួអង្គពាក់ព័ន្ធនឹងវិស័យជលផល
- កិច្ចសហប្រតិបត្តិការ៖ ការធ្វើការរួមគ្នារវាងស្ថាប័នរាជរដ្ឋាភិបាល ស្ថាប័នសេដ្ឋកិច្ច និងស្ថាប័នបរិស្ថាន
- ការគ្រប់គ្រងតាមស្ថានភាព៖ ពិនិត្យមើលលទ្ធផលដែលទទួលបាន និងសម្របតាមស្ថានភាព (ការរៀនសូត្រពីបទពិសោធន៍)
- ការគ្រប់គ្រងដោយត្រៀមបង្ការ៖ ការអនុវត្តស្របតាមធនធានដែលមាន។



**វិធីសាស្ត្រគ្រប់គ្រងតាមស្ថានភាព៖** វិធីសាស្ត្រនេះសំដៅដល់ការត្រួតពិនិត្យ និងវាយតម្លៃវិធានការគ្រប់គ្រងសរុបដោយប្រៀបធៀប ជាមួយនឹងយុទ្ធសាស្ត្រដែលបានអនុវត្តកន្លងមកនៅសហគមន៍នេសាទដទៃទៀត ដូចនេះមានន័យថាយុទ្ធសាស្ត្រត្រូវកែលម្អដោយឈរលើមេរៀន និងបទពិសោធន៍កន្លងមក។

**វិធីសាស្ត្រគ្រប់គ្រងតាមបែបត្រៀមបង្ការ៖** វិធីសាស្ត្រនេះសំដៅដល់ ការគិតគូរទុកជាមុន។ ឧទា . បើសិនជាសហគមន៍នេសាទអាចអនុញ្ញាតឱ្យដាក់លាន់អន្ទង់ចំនួន១០០យ៉ាងច្រើន និងតិចបំផុត ៧០នោះ សហគមន៍អាចឱ្យដាក់តែ៧០លាន់សិន។ បើសិនជាគេមានទិន្នន័យបង្ហាញកំណើនធនធានជលផល មានន័យថាផលស្តុកត្រីក៏មានកំណើនដែរ ពេលនោះសហគមន៍អាចអនុញ្ញាតបង្កើនចំនួនឧបករណ៍បន្ថែមទៀត។

## ៣. តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍នេសាទ

គណៈកម្មការសហគមន៍នេសាទមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងស្តីពីលក្ខន្តិក បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ប្រតិបត្តិស្របតាមលក្ខខណ្ឌនៅក្នុងលក្ខន្តិក បទបញ្ជាផ្ទៃក្នុង និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀត
- ស្វែងរកជំនួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុពីរដ្ឋបាលជលផល ស្ថាប័នពាក់ព័ន្ធ និងអ្នកជំនួយផ្សេងៗក្នុងការអនុវត្តដំណើរការសហគមន៍នេសាទ
- តំណាងឱ្យសហគមន៍នេសាទក្នុងការសម្រុះសម្រួលនិងដោះស្រាយទំនាស់ដែលកើតមាន
- បើកគណនីធនាគារ និងគ្រប់គ្រងហិរញ្ញវត្ថុសហគមន៍នេសាទ ដោយមានតម្លាភាព និងការទទួលខុសត្រូវ
- ធ្វើការសម្រេចចិត្តលើការអភិវឌ្ឍសហគមន៍នេសាទ ដោយមានការយល់ព្រមពីសមាជិកសហគមន៍នេសាទភាគច្រើនស្របទៅតាមលក្ខន្តិកសហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

- ចូលរួមពិគ្រោះយោបល់ក្នុងការធ្វើបទបញ្ញានានាដែលពាក់ព័ន្ធដល់ផលប្រយោជន៍របស់សហគមន៍នេសាទ
- រាយការណ៍ និងផ្តល់ព័ត៌មានជាបន្ទាន់នូវរាល់បទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍ដល់រដ្ឋបាលជលផលដែលនៅជិតបំផុត
- ធ្វើការអភិរក្ស និងការពារវារីជាតិនៅក្នុងកន្លែងនេសាទសហគមន៍
- អនុវត្តតួនាទីចាំបាច់ផ្សេងៗទៀត តាមការណែនាំរបស់រដ្ឋបាលជលផល
- ធ្វើការតវ៉ាចំពោះការមិនបន្តកិច្ចព្រមព្រៀងឱ្យសហគមន៍នេសាទ។



## គន្លឹះសម្រាប់អ្នកសម្របសម្រួល

សមាសភាពគណៈកម្មការសហគមន៍នេសាទរួមមាន៖ ប្រធាន អនុប្រធាន និងសមាជិក។ ចំនួននៃសមាជិកគណៈកម្មការជាចំនួនសេស(ពី៥ទៅ១១រូប)។ សមាជិកត្រូវបោះឆ្នោតជ្រើសរើសលេខាធិការមួយរូប និងហិរញ្ញិកមួយរូប។ ការបែងចែកការទទួលខុសត្រូវរបស់សមាជិកគណៈកម្មការនេសាទផ្សេងទៀត តាមតម្រូវការជាក់ស្តែង។

គណៈកម្មការសហគមន៍នេសាទត្រូវ៖

- រៀបចំក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រង ការអភិរក្ស ការអភិវឌ្ឍ និងការប្រើប្រាស់ធនធានជលផលរបស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព

- រៀបចំគោលការណ៍ និងយន្តការសម្រាប់ការដំណើរការសហគមន៍នេសាទ
- ការពារសិទ្ធ និងផលប្រយោជន៍សមាជិកសហគមន៍ និងផលប្រយោជន៍សាធារណៈ

គណៈកម្មការសហគមន៍នេសាទអនុវត្តលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ដើម្បីជានាថាការគ្រប់គ្រងរបស់ខ្លួនមានសណ្តាប់ធ្នាប់ និងមានប្រសិទ្ធភាព។

គណៈកម្មការសហគមន៍នេសាទអាចស្នើសុំជំនួយបច្ចេកទេសពីខណ្ឌរដ្ឋបាលជលផល ក្នុងការសម្របសម្រួលរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

គណៈកម្មការសហគមន៍នេសាទមានអាណត្តិ៥ឆ្នាំ គិតចាប់ពីថ្ងៃបោះឆ្នោត រហូតដល់ពេលដែលគណៈកម្មការសហគមន៍នេសាទថ្មីចូលជាធរមាន។

## ៤. គណៈកម្មការសហគមន៍នេសាទ និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

គណៈកម្មការសហគមន៍នេសាទមានភារកិច្ចរៀបចំ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍។ កិច្ចព្រមព្រៀងមានន័យថាបានទទួលស្គាល់ និងធានាសិទ្ធិរបស់សហគមន៍ចំពោះដែននេសាទដែលបានកំណត់ព្រំប្រទល់រួច។

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ត្រូវបានចុះហត្ថលេខាដោយខណ្ឌរដ្ឋបាលជលផល និងមានហត្ថលេខាជាសាក្សីរបស់មេឃុំ ចៅសង្កាត់។

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ត្រូវបញ្ជាក់ពីចំណុចសំខាន់ៗដូចខាងក្រោម៖

- ភាគីចុះកិច្ចព្រមព្រៀង
- ទំហំកន្លែងនេសាទ
- រយៈពេលគ្រប់គ្រង និងប្រើប្រាស់កន្លែងនេសាទ
- លក្ខខណ្ឌនៃការគ្រប់គ្រង និងប្រើប្រាស់កន្លែងនេសាទ

ក្រោយពីចុះហត្ថលេខា ត្រូវប្រថាប់ត្រារបស់ខណ្ឌរដ្ឋបាលជលផល។ កិច្ចព្រមព្រៀងនេះត្រូវចម្លងជូនសហគមន៍នេសាទ ក្រុមប្រឹក្សាឃុំ សង្កាត់ ខណ្ឌរដ្ឋបាលជលផល រដ្ឋបាលក្រុងស្រុកខណ្ឌ រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### គន្លឹះសម្រាប់អ្នកសម្របសម្រួល

ដើម្បីឱ្យកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍មានសុពលភាព ត្រូវមានការចុះហត្ថលេខាពីភាគីខណ្ឌរដ្ឋបាលជលផល និងគណៈកម្មការសហគមន៍នេសាទ ព្រមទាំងមានហត្ថលេខាជាសាក្សីរបស់មេឃុំ ចៅសង្កាត់។

## ៥. តួនាទីគណៈកម្មការសហគមន៍នេសាទ ក្នុងការធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ជារៀងរាល់ឆ្នាំ គណៈកម្មការសហគមន៍នេសាទត្រូវរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងធ្វើបច្ចុប្បន្នភាព៖

- កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

នៅក្នុងការពិនិត្យឡើងវិញ ត្រូវពិចារណាទៅលើ៖

- អាទិភាពនៃបញ្ហា ការគំរាមកំហែង និងគោលបំណង
- សកម្មភាពចម្បងៗដែលទាក់ទងទៅនឹងគោលបំណង

ដោយឡែកថវិកា និងឱកាសទទួលថវិកាក៏ត្រូវពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ។



# ៦. គណៈកម្មការសហគមន៍នេសាទ និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

## ៦.១ ការធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ចំណុចសំខាន់នៅក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍មានដូចខាងក្រោម៖

- តើមានគោលដៅ និងគោលបំណងអ្វីខ្លះ ដែលចង់សម្រេចឱ្យបាន?
- តើមានសកម្មភាពចម្បងៗអ្វីខ្លះ ដើម្បីសម្រេចគោលដៅ និងគោលបំណង?
- តើសង្ឃឹមថា នឹងទទួលបានលទ្ធផលអ្វីខ្លះ?
- តើត្រូវការរយៈពេលប៉ុន្មាន ក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ?
- តើអ្នកណាខ្លះជាអ្នកអនុវត្តសកម្មភាព?
- តើអ្នកណាជាអ្នកទទួលខុសត្រូវអនុវត្តសកម្មភាព?
- តើមានតម្រូវការហិរញ្ញវត្ថុប៉ុន្មាន និងប្រភពមកពីណា?



## គន្លឹះសម្រាប់អ្នកសម្របសម្រួល

នៅក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទបានបង្ហាញពីគំរូនៃការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល៣ឆ្នាំ។ វាជាគំរូទូទៅមួយដែលសហគមន៍នេសាទត្រូវបំពេញព័ត៌មានត្រង់ចន្លោះទំនេរ។ គំរូនោះដូចជាមិនបានផ្តល់ការណែនាំជាក់លាក់សម្រាប់ការរៀបចំទេ។ ហេតុនេះ ក្រុមបច្ចេកទេសនឹងផ្តល់បន្ថែមនូវគោលការណ៍ជាក់ស្តែងសម្រាប់រៀបចំផែនការ។

គោលបំណងនៃការរៀបចំផែនការគឺដើម្បីកំណត់៖

- គោលដៅ
- គោលបំណង
- យុទ្ធសាស្ត្រ និងសកម្មភាពគ្រប់គ្រងធនធានជលផល
- តួនាទី និងភារកិច្ចរបស់សហគមន៍នេសាទ និងស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាល។

នៅក្នុងផែនការគួរបញ្ចូល៖

- បញ្ហាសង្គម (ឧទា. ការវិវាទ សុខភាព សុវត្ថិភាព និងការកែច្នៃផលនេសាទ)
- ការប្រាស្រ័យទាក់ទង ជាមួយនឹងផ្នែកផ្សេងទៀត និងអ្នកពាក់ព័ន្ធ (ឧទា. ការបំពុលបរិស្ថាន និងតម្រូវការទីផ្សារ)
- បញ្ហាបរិស្ថាន (ឧទា. ផលប៉ះពាល់លើជម្រកពងកូនចំពោះប្រភេទត្រីខ្លះ)
- បញ្ហាអភិបាលកិច្ច (ឧទា. ដំណើរការពិគ្រោះយោបល់ និងការចូលរួមរបស់ស្ត្រី)

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទគឺមានសារៈសំខាន់ ដែលត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

## ៦.២ គណៈកម្មការសហគមន៍នេសាទណែនាំសមាជិកពីផ្នែកសំខាន់ៗនៃផែនការគ្រប់គ្រង

សហគមន៍នេសាទខ្លះមាន ខ្លះគ្មានផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។ ការរៀបចំផែនការដែលអាចអនុវត្តបាន គឺជាកិច្ចការមួយមិនងាយស្រួលពេកនោះទេ មួយវិញទៀតប្រកាសស្តីពីការណែនាំអំពីសហគមន៍នេសាទ ក៏មិនបានបង្ហាញលម្អិតអំពីដំណើរការ និងលក្ខណៈបច្ចេកទេសនៃការកសាងផែនការនោះដែរ។ បើទោះជាសហគមន៍ខ្លះមានផែនការក៏ដោយ តែផែនការនោះត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ដែលជាឱកាសកែសម្រួលនិងបន្ថែមសកម្មភាពចាំបាច់ជាក់ស្តែង ឱ្យត្រូវនឹងតម្រូវការ។

យើងនឹងពិនិត្យមើលអំពីខ្លឹមសារលម្អិតក្នុងផែនការល្អគួរមាន ដោយផ្តោតលើការងារជាក់ស្តែង និងអ្វីដែលសមាជិកគណៈកម្មការត្រូវដឹង ដើម្បីងាយស្រួលដឹកនាំសមាជិកសហគមន៍នេសាទឱ្យអនុវត្តសកម្មភាពចម្បងៗនៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

គណៈកម្មការ និងសមាជិកសហគមន៍នេសាទ និងតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីជំនាញជលផល រួមទាំងក្រុមស្ត្រី និងជនជាតិដើមភាគតិច ជួបជុំគ្នារៀបចំកិច្ចប្រជុំដើម្បីកសាង និងធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រង។ នេះជាឱកាសដ៏សំខាន់ដើម្បីប្រមូលមតិ និងយោបល់ឱ្យបានច្រើន។

ផែនការនេះបានកំណត់នូវយុទ្ធសាស្ត្រ និងសកម្មភាពគ្រប់គ្រងធនធានជលផល ក៏ដូចជាតួនាទី និងការទទួលខុសត្រូវក្នុងចំណោមដៃគូរួមមាន៖ សមាជិកគណៈកម្មការសហគមន៍នេសាទ សមាជិកសហគមន៍នេសាទ និងស្ថាប័នជំនាញរាជរដ្ឋាភិបាល។



## គន្លឹះសម្រាប់អ្នកសម្របសម្រួល

នៅពេលមានកិច្ចប្រជុំ ដើម្បីធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវអញ្ជើញក្រុមស្ត្រី និងជនជាតិដើមភាគតិចចូលរួមឱ្យបានច្រើន។ នៅដំណាក់កាលនេះ បើសិនជាមានអ្នកចូលរួមតិចល្មម គេអាចមានប្រើប្រាស់សម្ភារជំនួយងាយៗដើម្បីបង្រៀនដូចជា៖ រូបភាព ក្ដារខៀន ឬរូបត្ថុក។

### ៦.២.១ ទស្សនៈវិស័យរបស់សហគមន៍នេសាទ

ក្នុងអំឡុងពេលពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍នេសាទ គណៈកម្មការត្រូវសម្របសម្រួលក្រុមឱ្យបង្កើតទស្សនៈវិស័យ។ **ទស្សនៈវិស័យ**រៀបរាប់អំពីស្ថានភាពដែលគណៈកម្មការ និងសមាជិកសហគមន៍នេសាទចង់បាននាពេលអនាគត។

ឧទា. *“នៅឆ្នាំ២០៣០ ធនធានជលផលរបស់សហគមន៍យើងមាន៖ ១) ប្រព័ន្ធអេកូឡូស៊ីល្អប្រសើរ និង ២) ផ្ដល់នូវផលប្រយោជន៍ប្រកបដោយសមធម៌ដល់សមាជិកសហគមន៍ និងប្រជាពលរដ្ឋតាមរយៈកិច្ចសហការរួមគ្នា និងស្របច្បាប់ ក្នុងការគ្រប់គ្រងធនធានជលផលឱ្យមាននិរន្តរភាព”*។

ឬ *“ធ្វើឱ្យមាននិរន្តរភាពនូវធនធានជលផលនៅរយៈពេល២០ឆ្នាំទៀត សម្រាប់គ្រប់គ្រួសារសហគមន៍នេសាទ”*។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

ទស្សនៈវិស័យ គឺជាការរៀបរាប់អំពីស្ថានភាព ដែលសមាជិកសហគមន៍នេសាទ ចង់បាននៅពេលអនាគត ឬជាលទ្ធផល ដែលសហគមន៍នេសាទចង់សម្រេចឱ្យបានក្នុងរយៈពេលវែង។

ឧទា.

*សហគមន៍នេសាទរបស់យើងក្លាយជាសហគមន៍គំរូមួយ ដែលអាចយកទៅអនុវត្តនៅកន្លែងផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា។*

## ៦.២.២ ការកំណត់បញ្ហា និងការគំរាមកំហែង

នៅពេលពិគ្រោះយោបល់ គណៈកម្មការសហគមន៍នេសាទត្រូវបំផុសដល់សមាជិកសហគមន៍នេសាទលើកឡើងពីបញ្ហា និងការគំរាមកំហែងដែលទាក់ទងនឹងវិស័យជលផល។

កំណត់បញ្ហា និងការគំរាមកំហែងរួមមាន៖

- បញ្ហាបរិស្ថាន៖ កិច្ចការពារ និងស្តារជម្រកត្រី ការកាត់បន្ថយការបំពុលទឹក គ្រប់គ្រងកាកសំណល់ និងធនធានជលផល
- បញ្ហាសង្គម៖ សុវត្ថិភាពស្បៀង ការចិញ្ចឹមជីវិតដែលមាននិរន្តរភាព និងហេដ្ឋារចនាសម្ព័ន្ធជនបទ និង
- បញ្ហាអភិបាលកិច្ច៖ ការចូលរួម ការផ្តល់អំណាច និងពង្រឹងស្ថាប័នជាដើម។




**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

កន្លងមក ការធ្វើផែនការគ្រប់គ្រងធនធានជលផលគឺផ្តោតលើសកម្មភាពនេសាទតែប៉ុណ្ណោះ។ ដោយឡែកការគ្រប់គ្រងធនធានជលផលតាមបែបប្រព័ន្ធអេកូឡូស៊ីវិញ គឺការកំណត់បញ្ហា ការគំរាមកំហែង បញ្ហាផ្សេងៗទៀតក្រៅពីវិស័យជលផល (ឧទា. សកម្មភាពបំពុលបរិស្ថាននៅតំបន់ខ្ពង់រាប) និងបញ្ហានៃសកម្មភាពរបស់មនុស្ស (ឧទា. ហេដ្ឋារចនាសម្ពន្ធ័សហគមន៍)។

## ៦.២.៣ ការចាត់អាទិភាពបញ្ហា និងការគំរាមកំហែង

បន្ទាប់ពីកំណត់បញ្ហាត្រូវចាត់អាទិភាពបញ្ហា មានន័យថាជ្រើសរើសសកម្មភាពសំខាន់ៗ រួចកំណត់សកម្មភាពដែលសំខាន់ជាងគេ និងជាបន្តបន្ទាប់។ល។ ការងារនេះត្រូវរៀបទៅតាមលំដាប់លំដោយអាទិភាពនៃសកម្មភាពនីមួយៗ។




### គន្លឹះសម្រាប់អ្នកសម្របសម្រួល

នៅពេលដែលបញ្ហា និងការគំរាមកំហែងបានរកឃើញបញ្ហាយ៉ាងច្រើន ប៉ុន្តែមានតែបញ្ហាមួយចំនួនប៉ុណ្ណោះ ដែលអាចដោះស្រាយបានតាមរយៈគោលការណ៍នៃការគ្រប់គ្រងធនធានជលផល។

ការចាត់អាទិភាព តម្រូវឱ្យមានការវាយតម្លៃ អំពីភាពធ្ងន់ធ្ងរ និងហានិភ័យដែលទាក់ទងនឹងបញ្ហា និងការគំរាមកំហែងនីមួយៗ។ នៅដំណាក់កាលចាត់អាទិភាព គេអាចដាក់ពិន្ទុ និងធ្វើការចាត់ថ្នាក់ឱ្យបញ្ហានីមួយៗដែលមានដល់ឥទ្ធិពលមកលើសហគមន៍ និងមកលើប្រព័ន្ធវារីអេកូឡូស៊ី។

## ៦.២.៤ ការកំណត់តម្រូវការ និងចាត់អាទិភាព

គណៈកម្មការសហគមន៍នេសាទត្រូវសម្របសម្រួលជាមួយសមាជិក ក្នុងការកំណត់តម្រូវការ និងចាត់អាទិភាព ដែលឆ្លើយតបនឹងបញ្ហា និងការគំរាមកំហែងដែលរកឃើញខាងលើ។ នេះជាផ្នែកមួយសំខាន់ ពីព្រោះវានឹងកំណត់នូវសកម្មភាពចម្បងៗ ដែលឆ្លើយតបនឹងតម្រូវការ។

*ការកំណត់តម្រូវការ ដែលទាក់ទងជាមួយបញ្ហានិងការគំរាមកំហែង ៖*

បញ្ជីតម្រូវការត្រូវរៀបចំឱ្យច្បាស់លាស់ និងមានចំនួនជាក់លាក់ ដោយផ្តោតលើតម្រូវការណាដែលគណៈកម្មការ និងសមាជិកសហគមន៍នេសាទអាចត្រូវដោះស្រាយ។

*ការចាត់អាទិភាពតម្រូវការដែលទាក់ទងនឹងបញ្ហានិងការគំរាមកំហែង៖*

បន្ទាប់ពីកំណត់តម្រូវការរួច ត្រូវចាត់អាទិភាព។ នៅពេលចាត់អាទិភាព ត្រូវរកតម្រូវការសំខាន់ដែលចាំបាច់ ចម្បង បន្ទាន់ជាងគេ និងជ្រើសរើសជាបន្តបន្ទាប់ តាមលំដាប់លំដោយ ដើម្បីឱ្យសហគមន៍នេសាទឆ្លើយតបនឹងតម្រូវការ និងដែលទទួលបានលទ្ធផលល្អ។



## ៦.២.៥ ការកំណត់គោលដៅ និងគោលបំណង

បន្ទាប់មក គណៈកម្មការសហគមន៍នេសាទជួយសមាជិកកំណត់*គោលដៅ និង គោលបំណងជាក់លាក់*ដែលឆ្លើយតបនឹងបញ្ហាជាអាទិភាព។

*ការកំណត់គោលដៅរួមនៃការគ្រប់គ្រងធនធានជលផល៖*

គោលដៅត្រូវមានទំនាក់ទំនងជាមួយនឹងបញ្ហា និងការគំរាមកំហែង។ ដូចគ្នានឹងបញ្ហា និងការគំរាមកំហែងដែរ គោលដៅចែកចេញជា៖ ១)គោលដៅផ្នែកបរិស្ថាន ២)គោលដៅផ្នែកសង្គម និង ៣)គោលដៅផ្នែកអភិបាលកិច្ច។

គោលដៅដែលល្អ គឺមានលក្ខណៈទូទៅ ខ្លីៗ ប្រាកដប្រជា។

ឧទា. សហគមន៍នេសាទចង់ធ្វើការធ្វើឱ្យប្រសើរឡើងនូវធនធានជលផល ដើម្បីបង្កើនចំណូលរបស់ប្រជាពលរដ្ឋក្នុងសហគមន៍។

*គោលបំណងត្រូវរៀបចំឡើង ស្របតាមគោលដៅ និងឆ្លើយតបនឹងបញ្ហានានា៖* បើសិនជាការកំណត់បញ្ហាបានជាក់លាក់ វាក៏មានភាពងាយស្រួល ក្នុងការបង្កើតគោលបំណងដែរ។ ឧទា.ខាងក្រោមបង្ហាញពីមែកធាងនៃគោលបំណង។ ឧទា.

ទស្សនៈវិស័យ គោលដៅ គោលបំណង



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

**គោលដៅ** គឺជាការរៀបរាប់ទូទៅអំពីចំណុចដៅ ដែលសហគមន៍នេសាទនឹងអនុវត្ត (អ្វីដែលអាចនឹងសម្រេចបានពីការអនុវត្តសកម្មភាព)។

**គោលបំណង** ត្រូវបានបង្កើតឡើងដោយផ្អែកលើការគំរាមកំហែង បញ្ហា និងតម្រូវការ ដែលឆ្លើយតបដល់គោលដៅ។ ប្រសិនបើការគំរាមកំហែង បញ្ហា ឬតម្រូវការត្រូវបានកំណត់យ៉ាងច្បាស់នោះ វាមិនគួរមានការលំបាកក្នុងការបង្កើតគោលបំណងនោះទេ។

វិធីសរសេរគោលបំណងមានមានលក្ខណៈ ស្មាត (SMART)៖

| | | |
|---|---|---|
| S | Specific | ច្បាស់លាស់ / ចំៗ |
| M | Measurable | អាចវាស់វែងបាន (លទ្ធផលធៀបនឹងសូចនាករ) |
| A | Agreed | ឯកភាពពីគ្រប់អ្នកពាក់ព័ន្ធភាគច្រើន |
| R | Realistic | ពិតប្រាកដ (អាចអនុវត្តបាន និងធនធានគ្រប់គ្រាន់) |
| T | Time dependent | កំណត់ពេលវេលាដាក់លាក់សម្រាប់សកម្មភាពចម្បងៗ |

## ៦.២.៦ ការកំណត់វិធានការគ្រប់គ្រង

គណៈកម្មការសហគមន៍នេសាទត្រូវជួយសមាជិកកំណត់វិធានការគ្រប់គ្រង សម្រាប់គោលបំណងនីមួយៗ។

វិធានការគ្រប់គ្រង គឺជាសកម្មភាពនានា ដើម្បីសម្រេចគោលបំណង។ ឧទា. វិធានការគ្រប់គ្រងអាចជាការដាក់កម្រិតការប្រើប្រាស់ឧបករណ៍នេសាទ និងរដូវបិទនេសាទជាដើម។

សម្រាប់គោលបំណងនីមួយៗ ត្រូវកំណត់៖

- លទ្ធផលរំពឹងទុក (បង្កើតអ្វី ឬមានអ្វីដែលផ្លាស់ប្តូរ)
- ពេលវេលា (តើយុទ្ធសាស្ត្រ ត្រូវបានអនុវត្តក្នុងអំឡុងពេលណា?)
- អ្នកអនុវត្តសកម្មភាព (តម្រូវការកិច្ចសហប្រតិបត្តិការ ក្នុងការអនុវត្តសកម្មភាព)
- អ្នកទទួលខុសត្រូវ ឬស្ថាប័នអនុវត្តសកម្មភាព (អ្នកទទួលខុសត្រូវ ចំពោះការអនុវត្ត)
- តម្រូវការ និងប្រភពហិរញ្ញវត្ថុ។




## គន្លឹះសម្រាប់អ្នកសម្របសម្រួល

គោលបំណងមួយត្រូវរៀបចំសកម្មភាពចម្បងៗ ដោយពិចារណាលើភាពងាយស្រួលអនុវត្តន៍ ជានាជោគជ័យ តាមលទ្ធភាព និងការចំណាយ។ បណ្តុំសកម្មភាពចម្បងៗ ហៅថាយុទ្ធសាស្ត្រ។

ក្នុងការអនុវត្តយុទ្ធសាស្ត្រទាំងឡាយ ត្រូវការចៀសវាងការបាត់បង់ផលប្រយោជន៍របស់សមាជិកសហគមន៍នេសាទ រួមទាំងផលប្រយោជន៍របស់ក្រុមស្ត្រី និងជនជាតិដើមភាគតិច។ល។

វិធានការគ្រប់គ្រង គឺជាឧបករណ៍ចាំបាច់ដើម្បីសម្រេចគោលបំណង។ នៅក្នុងស្ថានភាពដែលមានវិធានការមួយ ឬច្រើន ហៅថាជាយុទ្ធសាស្ត្រ។ បណ្តុំនៃវិធានការគឺសម្រាប់កាត់បន្ថយការគំរាមកំហែង ឬដោះស្រាយបញ្ហានានា។ ឧទា. ក្នុងការគ្រប់គ្រងធនធានជលផល វិធានការគ្រប់គ្រងអាចរួមបញ្ចូលវិធានការបច្ចេកទេសដូចជា៖ កំណត់ប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើនេសាទក្នុងដែននេសាទ និងកំណត់រដូវបិទនេសាទ ដើម្បីការពារជម្រកត្រីពងកូនជាដើម។ ការរួមបញ្ចូលគ្នានៃខ្លឹមសារខាងលើមានន័យថា ជាយុទ្ធសាស្ត្រនៃការគ្រប់គ្រង។

## ៦.៣ បញ្ហាយេនឌ័រ និងជនជាតិដើមភាគតិច ក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គណៈកម្មការសហគមន៍នេសាទត្រូវគិតគូរអំពីសកម្មភាពដែលទាក់ទងនឹង*ស្ត្រី ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះ* ដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

កិច្ចប្រជុំជាមួយក្រុមស្ត្រីគួរត្រូវបានរៀបចំដោយឡែក ដើម្បីកំណត់បញ្ហាតម្រូវការ និងឱកាសរបស់ស្ត្រី រួចដាក់បញ្ចូលបញ្ហា តម្រូវការ និងឱកាសទាំងនោះទៅក្នុងផែនការគ្រប់គ្រង។

គណៈកម្មការសហគមន៍នេសាទត្រូវពិនិត្យមើលដូចជា៖

- គោលដៅ និងគោលបំណង ដែលឆ្លើយតបនឹងតម្រូវការរបស់ស្ត្រី និងជនជាតិដើមភាគតិច
- សកម្មភាពនានា ដែលលើកកម្ពស់ការចូលរួមរបស់ស្ត្រី និងជនជាតិដើមភាគតិច ក្នុងសហគមន៍ និងគណៈកម្មការសហគមន៍នេសាទ
- លទ្ធផលត្រូវសម្រេចឱ្យបានតាមករណីនីមួយៗ
- ការគ្រោងវិនិយោគ ដើម្បីសម្រេចគោលបំណង
- អ្នកទទួលខុសត្រូវ/ ក្រុមតាមដានលទ្ធផល។



## ៧. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការគ្រប់គ្រង

ការគ្រប់គ្រងសហគមន៍នេសាទ គឺជាដំណើរការជាបន្តបន្ទាប់ ដើម្បីសម្រេចគោលបំណងដែលបានគ្រោងទុក។

ជាធម្មតា ត្រូវតែមានការតាមដានត្រួតពិនិត្យ ថាតើផែនការត្រូវបានអនុវត្តតាមការគ្រោងទុកដែរឬទេ? ហើយក៏ត្រូវតែមានការវាយតម្លៃ ថាតើអ្វីជាជោគជ័យ និងបរាជ័យ ព្រមទាំងការរៀនសូត្រពីបទពិសោធន៍យ៉ាងដូចម្ដេច?

ការវាយតម្លៃរួមមានការពិនិត្យមើលលទ្ធផលនៃសកម្មភាពដែលបានអនុវត្ត និងប៉ាន់ប្រមាណថាតើសកម្មភាពទាំងនោះទទួលបានផ្លែផ្កា (លទ្ធផលរយៈពេលវែង) - កិច្ចការនេះជួយឱ្យមានភាពបត់បែន និងធ្វើឱ្យប្រសើរឡើងតាមរយៈការរៀនសូត្រ។



### គន្លឹះសម្រាប់អ្នកសម្របសម្រួល

ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ គឺជាដំណើរការដែលឆ្លើយតបទៅនឹងសំណួរ "ថាតើការអនុវត្តវិធានការគ្រប់គ្រងបានត្រឹមត្រូវដែរឬទេ?" បើសិនជាមិនត្រឹមត្រូវ "តើវិធានការគ្រប់គ្រងរបៀបណាដែលត្រឹមត្រូវ?"

ការតាមដានត្រួតពិនិត្យ និងវាយតម្លៃបានត្រឹមត្រូវ អាចទទួលបានផែនការគ្រប់គ្រងល្អ គឺមានន័យថាការរៀនសូត្រពីបទពិសោធន៍។

## ៨. គណៈកម្មការសហគមន៍នេសាទ និងការគ្រប់គ្រងវិវាទ

នៅក្នុងអាណត្តិ៥ឆ្នាំរបស់ខ្លួន គណៈកម្មការសហគមន៍នេសាទអាចជួបនឹងវិវាទមួយចំនួន។

គណៈកម្មការសហគមន៍ត្រូវត្រៀមខ្លួនដោះស្រាយវិវាទរវាងសមាជិកសហគមន៍ និងប្រជាពលរដ្ឋ និងរវាងសហគមន៍នេសាទ និងអ្នកខាងក្រៅ។

គណៈកម្មការសហគមន៍នេសាទត្រូវទទួលស្គាល់ថា ភាគីវិវាទមានទស្សនៈផ្ទុយគ្នាអំពីដំណោះស្រាយជាក់លាក់ ហើយទស្សនៈរបស់ភាគីនីមួយៗតែងមានហេតុផលរៀងៗខ្លួន។

គោលដៅនៃការគ្រប់គ្រងមិនមែនមានន័យថាគេចវេសពីវិវាទនោះទេ តែវាមានន័យថាភាគីទាំងអស់រួមគ្នាដោះស្រាយ។

ការគ្រប់គ្រងវិវាទរួមមាន៖

- **ការចរចា៖** ភាគីជួបគ្នាទល់មុខ ជួនកាលមាន ឬគ្មានអ្នកសម្របសម្រួល ឈានដល់ឯកភាពលើដំណោះស្រាយសមស្របមួយចំនួន
- **ការសម្រុះសម្រួល៖** អ្នកសម្រុះសម្រួល (ភាគីទី៣អព្យាក្រិត) ជួយភាគីក្នុងវិវាទឈានដល់ការចរចា តែគាត់មិនមានអំណាចបង្ខំភាគីទាំងពីរឱ្យយកដំណោះស្រាយណាមួយទេ
- **ការផ្សះផ្សា៖** អ្នកសម្រុះសម្រួលអព្យាក្រិតជួបភាគីដោយឡែកពីគ្នា ដើម្បីបន្ថយកំហឹង និងឯកភាពចំពោះដំណើរការដោះស្រាយ
- **អាជ្ញាកណ្តាល៖** ជួបជាមួយភាគីវិវាទ និងមានសិទ្ធិឱ្យភាគីទទួលយកដំណោះស្រាយ

យន្តការដោះស្រាយវិវាទរួមមាន៖

ការដោះស្រាយវិវាទដំបូងៗ (ពេលដែលភាគី ទាំងអស់ត្រៀមខ្លួននឹងដោះស្រាយ)

- អ្នកណាជាអ្នកជួយដោះស្រាយ
- អ្នកណាជាអ្នកសម្រេច ក្នុងករណីដែលមិនមានការឯកភាពគ្នា

វិវាទធំៗ (ពេលដែល ភាគីទាំងអស់ទំនងជាមិនឯកភាពគ្នា)

- អ្នកណាជាអ្នកជួយដោះស្រាយ
- អ្នកណាជាអ្នកសម្រេច ក្នុងករណីដែលមិនមានការឯកភាពគ្នា។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ (ជំពូកទី ១១ ប្រការ ៣៣) ចែងថា "វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទត្រូវបានដោះស្រាយដូចខាងក្រោម៖

- គណៈកម្មការសហគមន៍នេសាទត្រូវសម្របសម្រួល និងដោះស្រាយរាល់វិវាទ ដែលកើតឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន
- ក្នុងករណី គណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទពុំបានសម្រេច ត្រូវតែបញ្ជូនសំណុំរឿងនោះទៅសមត្ថកិច្ចរដ្ឋបាលជលផលដើម្បីដោះស្រាយឋានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាននិងមន្រ្តីពាក់ព័ន្ធតាមការចាំបាច់
- ក្នុងករណីដែលបញ្ហាវិវាទនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និងរដ្ឋបាលជលផលត្រូវតែបញ្ជូនសំណុំរឿងទៅតុលាការខេត្ត ក្រុងសាមី ដើម្បីដោះស្រាយតាមច្បាប់ "។

ការបង្កើតយន្តការដោះស្រាយវិវាទពីដំណាក់កាលដំបូង នៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ នឹងជួយកសាងទំនុកចិត្ត និងចៀសវាងវិវាទដែលនឹងត្រូវចំណាយពេលវេលា ថវិកាក្នុងដំណើរការអនុវត្តផែនការ។ សហគមន៍នេសាទដែលរួមបញ្ចូលយន្តការគ្រប់គ្រងវិវាទទំនងជាទទួលបានជោគជ័យច្រើន ក្នុងការសម្រេចគោលបំណងនៃការគ្រប់គ្រង គោលដៅបរិស្ថាន និងសង្គម ជាជាងសហគមន៍នេសាទដែលមិនមានយន្តការគ្រប់គ្រងវិវាទ។

## ៩. តួនាទីគណៈកម្មការសហគមន៍នេសាទចំពោះការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់

ការពង្រឹងការអនុវត្តច្បាប់រួមមាន វិធីសាស្ត្រច្រើនក្នុងការផ្លាស់ប្តូរផ្នត់គំនិតរបស់ជនល្មើស។ អន្តរាគមន៍ពង្រឹងការអនុវត្តច្បាប់ អាចជាវិធានការបង្ការទន់ភ្លន់ ឬទណ្ឌកម្មធ្ងន់ធ្ងរ។

**វិធានការទន់ភ្លន់** ជំរុញការអនុវត្តច្បាប់ដោយស្ម័គ្រចិត្ត យោងតាមលិខិតបទដ្ឋានគតិយុត្ត ។ វិធីសាស្ត្របែបវិជ្ជមាននេះរួមមាន៖ រៀបចំទិវាសំខាន់ៗ កិច្ចប្រជុំសាធារណៈ ទស្សនកិច្ចសិក្សា ការចែករំលែកបទពិសោធន៍ ជំរុញការអនុវត្តល្អៗ និងកម្មវិធីតាមសាលា។

**វិធានការក្តៅ** ប្រើប្រាស់ការត្រួតពិនិត្យនិងទណ្ឌកម្ម និងចំណាយច្រើនជាងការពង្រឹងការអនុវត្តច្បាប់។ វាជាដំណើរការបន្តបន្ទាប់នៃការល្បាត និងការចាប់ចងជនល្មើស។ ក្រៅពីវិធានការក្តៅ គណៈកម្មការសហគមន៍នេសាទគួរពិចារណាផងដែរអំពីវិធានការទន់ភ្លន់ ហើយក៏ត្រូវកំណត់អ្នកទទួលខុសត្រូវក្នុងការពង្រឹងការអនុវត្តច្បាប់។

### គន្លឹះសម្រាប់អ្នកសម្របសម្រួល

ការពង្រឹងការអនុវត្តច្បាប់ មានន័យថាប្រសើរជាជាងការបង្ក្រាបចាប់ជនល្មើសដោយសមត្ថកិច្ច។ កិច្ចការនេះរួមមានការអនុវត្តវិធីសាស្ត្រនានារបស់ស្ថាប័នផ្សេងៗ និងអ្នកពាក់ព័ន្ធ ដើម្បីធ្វើឱ្យជនល្មើសរាងចាល។

ការពង្រឹងការអនុវត្តច្បាប់អាចជាវិធានការបង្ការ "ទន់ភ្លន់" ឬការដាក់ទណ្ឌកម្ម "ធ្ងន់ធ្ងរ"។ ការអនុវត្តច្បាប់ទន់ភ្លន់ជំរុញឱ្យមានការអនុវត្តតាមការស្ម័គ្រចិត្តស្របតាមលក្ខខណ្ឌនៃច្បាប់ដោយមិនចាំបាច់ទៅតុលាការ។ ការអនុវត្តច្បាប់ទន់ភ្លន់ ផ្តោតលើសក្តានុពលសង្គម និងវប្បធម៌នៃការអនុលោមទៅតាមដែលអាចត្រូវបានប្រើប្រាស់ដើម្បី៖ ក) គាំទ្រដល់ការគោរពច្បាប់ទូលំទូលាយ ខ) លើកទឹកចិត្តគោរពស្ម័គ្រចិត្ត និង គ) សម្រេចបានការបង្ការទូទៅ។

វិធានការទន់ភ្លន់រួមមាន៖

- ការផ្សព្វផ្សាយក្នុងសង្គម ដូចជាការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទំនាក់ទំនងសាធារណៈ ការប្រាស្រ័យទាក់ទង ការចូលរួមពីបុគ្គលល្បី (តារាកំប្លែង អ្នកជំនាញ វាគ្មិនកិត្តិយស) និងការស្វែងរកការគាំទ្រមតិ

- ការប្រាស្រ័យទាក់ទងសង្គមដូចជា៖ សិក្ខាសាលា កិច្ចប្រជុំ ទស្សនកិច្ចសិក្សា ទស្សនកិច្ចផ្លាស់ប្តូរ បទពិសោធន៍ ការស្វែងរកការគាំទ្រមតិ វេទិកាសាធារណៈ ការសម្តែងរឿងខ្លីៗ គណៈកម្មការសហគមន៍នេសាទ ក្រុមល្បាត ក្រុមឃ្លាំមើល និងការបញ្ចូលក្នុងកម្មវិធីសិក្សា ជាដើម
- ការអប់រំ និងការផ្សព្វផ្សាយព័ត៌មានដល់មូលដ្ឋាន តាមរយៈទូរទស្សន៍ វីដេអូ កាសែត ព្រឹត្តប័ត្រព័ត៌មាន កំប្លែង រូបភាព និងព័ត៌មាន
- ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។

វិធានការតឹងរ៉ឹង ដែលអនុវត្តដោយអាជ្ញាធរមានសមត្ថកិច្ច និងតុលាការ ដើម្បីឱ្យជនល្មើសរាងចាល។ វិធានការនេះមានគោលបំណង ដើម្បីកំណត់ជនល្មើស កំណត់ទីតាំង និងបង្ក្រាបជនល្មើសដោយប្រើប្រាស់គ្រប់រូបភាពនៃទិដ្ឋភាពច្បាប់ ។ វិធានការក្តៅរួមមាន៖

- ការពង្រឹងការអនុវត្តច្បាប់ជាបន្តបន្ទាប់ ដូចជាការល្បាតជាដើម
- សកម្មភាពស្វែងរកជាប្រចាំ ចាប់ជនល្មើស និងបញ្ជូនទៅតុលាការ និងដាក់ទណ្ឌកម្មតាមបទល្មើសជាក់ស្តែង
- មានយុទ្ធសាស្ត្រផ្សេងៗដែលប្រសើរសម្រាប់ដេញចាប់ជនល្មើសដែលមិនរាងចាល តាមរយៈ ក្រុមល្បាត ឬទូកប្រដេញ ប្រព័ន្ធត្រួតពិនិត្យ ធ្វើការរឹបអូសសម្ភារ ឧបករណ៍នេសាទពាក់ព័ន្ធនឹងសកម្មភាពនេសាទល្មើសច្បាប់។

## ១០. តួនាទីនៃគណៈកម្មការសហគមន៍នេសាទក្នុងការរៀបចំថវិកា

ភាពគ្រប់គ្រាន់ ភាពទាន់ពេលវេលា ធនធានហិរញ្ញវត្ថុមាននិរន្តរភាព ជាកត្តាគន្លឹះ ក្នុងការគាំទ្រដល់ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។ គណៈកម្មការសហគមន៍នេសាទមានតួនាទីសំខាន់ក្នុងការធានាធនធានហិរញ្ញវត្ថុមាននិរន្តរភាព ចំពោះផែនការ និងសកម្មភាពនានា។

សហគមន៍នេសាទតម្រូវឱ្យមានប្រភពធនធានហិរញ្ញវត្ថុ។ ផែនការថវិកាត្រូវផ្អែកលើការវាយតម្លៃស្តីពីការប្រតិបត្តិការ។

គណៈកម្មការសហគមន៍នេសាទត្រូវការធនធានហិរញ្ញវត្ថុ។ ផែនការថវិកាត្រូវរៀបចំឡើងដោយឈរលើមូលដ្ឋាននៃការវាយតម្លៃរាល់ការចំណាយចំពោះសកម្មភាពនានា។ សហគមន៍នេសាទត្រូវកំណត់៖

- **ការចំណាយលើសកម្មភាពសំខាន់ៗ** ដូចជាចំណាយលើហេដ្ឋារចនាសម្ព័ន្ធ សម្ភារឧបករណ៍ ( ទូកល្បាត ឧបករណ៍ត្រួតពិនិត្យ និងទំនាក់ទំនង ) និងចំណាយប្រតិបត្តិការរួមមាន ប្រេង អាហារ និងចំណាយលើកិច្ចប្រជុំជាដើម។
- **ប្រភពហិរញ្ញវត្ថុ**ដូចជា៖ ជំនួយរបស់រាជរដ្ឋាភិបាល អំណោយ និងជំនួយ ចំណូលពីទេសចរណ៍ ចំណូលពីសិប្បកម្ម និងចំណូលក្រុមសន្សំ ឬពីឥណទាន
- **ពេលវេលាគ្រោងទុកនៃការចំណាយ និងចំណូល** ដើម្បីងាយស្រួលក្នុងការព្យាករណ៍ចរន្តថវិកាឱ្យទាន់ពេលវេលា។

ប្រភពធនធានហិរញ្ញវត្ថុមាននិរន្តរភាពរួមមាន៖

- ចំណូលពីទេសចរណ៍ (សំបុត្រចូលទស្សនា និងជិះទូកកំសាន្ត ថ្លៃស្នូចត្រីលំហែ... )
- ជំនួយ និងអំណោយ (ភ្នាក់ងារផ្តល់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន...)
- ចំណូលពីសិប្បកម្ម (របស់របរធ្វើដោយដៃ ផលិតផល វត្ថុអនុស្សាវរីយ៍)
- ចំណូលពីក្រុមសន្សំប្រាក់ ឬឥណទានខ្នាតតូច
- ជំនួយពីរាជរដ្ឋាភិបាល និងប្រភពផ្សេងទៀត...។



## គន្លឹះសម្រាប់អ្នកសម្របសម្រួល

ធនធានហិរញ្ញវត្ថុមានសារសំខាន់ ចំពោះផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងជាកត្តា គន្លឹះ សម្រាប់សម្រេចបាននិរន្តរភាពរយៈពេលវែង។ ហិរញ្ញវត្ថុត្រូវតែមានគ្រប់គ្រាន់ សម្រាប់ចំណាយប្រតិបត្តិការ ដែលទាក់ទងនឹងផែនការ ការអនុវត្ត ការសម្របសម្រួល តាមដានត្រួតពិនិត្យ និងការពង្រឹងការអនុវត្តច្បាប់។

ផែនការថវិកាមាននិរន្តរភាពជាផ្នែកមួយដ៏សំខាន់ នៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។ ដើម្បីឱ្យសហគមន៍មានដំណើរការល្អ ត្រូវគិតអំពីធនធានហិរញ្ញវត្ថុមាននិរន្តរភាពតាំងពីដំបូង។

ផែនការថវិកាត្រូវបានរៀបចំឡើង ដោយឈរលើការវាយតម្លៃទៅលើចំណាយប្រតិបត្តិការចំពោះសកម្មភាពនានា នៃផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទទាំងរយៈពេលវែង និងខ្លី។

## ១១. តួនាទីគណៈកម្មការសហគមន៍នេសាទក្នុងការរៀបចំផែនការសកម្មភាព និងរបាយការណ៍

### ១១.១ ការរៀបចំផែនការសកម្មភាព

ដោយឈរលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ **ផែនការសកម្មភាព**គឺជាការកំណត់នូវសកម្មភាព តម្រូវការ និងបញ្ហាសំខាន់ៗ ដែលត្រូវដោះស្រាយក្នុងរយៈពេល៣ខែ។

ផែនការសកម្មភាពបញ្ជាក់នូវ៖

- សកម្មភាពគ្រោង
- លទ្ធផលសកម្មភាព
- តម្រូវការសម្ភារ
- អ្នកទទួលខុសត្រូវអនុវត្ត
- ទីកន្លែង និងពេលវេលា
- ថវិកា។

គណៈកម្មការសហគមន៍នេសាទត្រូវរៀបចំផែនការសកម្មភាព និងពិនិត្យឡើងវិញជារៀងរាល់ខែ នៅពេលមានកិច្ចប្រជុំ។ ផែនការសកម្មភាពត្រូវត្រួតពិនិត្យជារៀងរាល់៣ខែម្តង ទន្ទឹមនឹងផែនការថ្មីបានរៀបចំឡើង។

**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

ផែនការសកម្មភាពរបស់សហគមន៍រៀបចំឡើង ដោយផ្អែកលើអនុក្រឹត្យស្តីពីសហគមន៍នេសាទដែលតម្រូវឱ្យសហគមន៍មានផែនការសកម្មភាពរបស់ខ្លួន ក៏ដូចជាផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

ផែនការសកម្មភាពរួមមាន៖

- ការពិនិត្យមើលសកម្មភាព ដែលគណៈកម្មការសហគមន៍នេសាទបានអនុវត្តកន្លងមក
- កំណត់បញ្ហាសំខាន់ៗ ដែលមិនទាន់ដោះស្រាយ និងបន្តដោះស្រាយ
- ការចាត់អាទិភាពបញ្ហា

- កំណត់សកម្មភាពសំខាន់ៗ និងធាតុនានារបស់ផែនការ
- សំណើការគាំទ្រពីអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ
- ការអនុវត្តសកម្មភាព និងការតាមដានត្រួតពិនិត្យ។

## ១១.២ ការធ្វើរបាយការណ៍

គណៈកម្មការសហគមន៍នេសាទត្រូវរៀបចំ**របាយកាណ៍**រៀងរាល់ ៣ ខែម្ដង ជូនខណ្ឌរដ្ឋបាលជលផលតាមរយៈផ្នែករដ្ឋបាលជលផល និងចម្លងជូនក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវរក្សាទុកនៅគណៈកម្មការសហគមន៍នេសាទ។

គម្រូរបាយការណ៍របស់សហគមន៍នេសាទត្រូវកំណត់ដោយរដ្ឋបាលជលផលដែលរៀបរាប់ពីចំណុចសំខាន់ៗជាអាទិ៍ដូចខាងក្រោម៖

- លទ្ធផលនៃការអនុវត្តកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- លទ្ធផលនៃការអនុវត្តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សកម្មភាពរីកចំរើនរបស់សហគមន៍នេសាទ
- សង្ខេបអំពីស្ថានភាពចំណូល និងការចំណាយថវិការបស់គណៈកម្មការសហគមន៍នេសាទ
- បញ្ហាដែលបានជួបប្រទះ និងអនុសាសន៍សម្រាប់កែលម្អ
- ទិសដៅ និងសកម្មភាពការងារសម្រាប់អនុវត្តក្នុងខែ ត្រីមាស ឆមាស និងឆ្នាំបន្ទាប់។



## ១២. កិច្ចសហការជាមួយខណ្ឌរដ្ឋបាលជលផល

គណៈកម្មការសហគមន៍នេសាទធ្វើការជាមួយ ខណ្ឌរដ្ឋបាលជលផលលើកិច្ចការមួយចំនួន ដូចជា៖ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ការពង្រឹង ការអនុវត្តច្បាប់ និងរបាយការណ៍។



គណៈកម្មការសហគមន៍នេសាទត្រូវស្គាល់អ្នកទទួលបន្ទុករបស់ខណ្ឌរដ្ឋបាលជលផល និង អញ្ជើញ ពួកគាត់ឱ្យចូលរួមកិច្ចប្រជុំ និងសកម្មភាពផ្សេងៗរបស់សហគមន៍ ដើម្បីឱ្យពួកគាត់ដឹងអំពី សហគមន៍នេសាទ។ ការប្រាស្រ័យទាក់ទងដែលមានលក្ខណៈបើកចំហ គឺជានាំនូវភាពជោគជ័យរបស់ សហគមន៍នេសាទ។

ខណ្ឌរដ្ឋបាលជលផលមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- យល់ព្រម និងឯកភាពលើកិច្ចព្រមព្រៀង
- សង្កេតការណ៍ដំណើរការបោះឆ្នោតគណៈកម្មការសហគមន៍នេសាទ
- យល់ព្រមលើបច្ចុប្បន្នភាពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ប្រថាប់ត្រាលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ពិនិត្យ និងយល់ព្រមលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ពិគ្រោះយោបល់អំពីការកំណត់ព្រំប្រទល់ និងផែនទីសហគមន៍នេសាទ
- ពិនិត្យរបាយការណ៍ប្រចាំត្រីមាស និងរបាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍

- ប្តូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស ដាក់ជូនរដ្ឋបាលជលផល ថ្នាក់កណ្តាល
- ផ្តល់ជំនួយបច្ចេកទេស និងប្រឹក្សាយោបល់ដល់សហគមន៍នេសាទ ដូចជាការផ្សព្វផ្សាយ បំផុស និងការផ្តល់អំណាចជាដើម
- បង្កើត និងកែសម្រួលគោលនយោបាយ និងផែនការអភិវឌ្ឍន៍ ដែលទាក់ទងនឹង សហគមន៍នេសាទ
- បង្កើតផែនការសកម្មភាពគ្រប់គ្រង
- សម្របសម្រួលការអនុវត្តផែនការជាមួយសហគមន៍នេសាទ
- តាមដានត្រួតពិនិត្យសកម្មភាពរបស់សហគមន៍នេសាទ
- ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- ជួយសម្របសម្រួលវិវាទ
- វាយតម្លៃលទ្ធផលនៃការអនុវត្តផែនការ។

## ១៣. ការបញ្ចូលលទ្ធផលផែនការគ្រប់គ្រងទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

លទ្ធផលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការ អភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដើម្បីឱ្យឃុំ សង្កាត់ កៀរគរធនធានទាំងក្នុង និងក្រៅមូលដ្ឋាន និងសម្រេចអំពីការប្រើប្រាស់ធនធាននោះក្នុងការដោះស្រាយបញ្ហា និងបម្រើផលប្រយោជន៍ របស់ប្រជាពលរដ្ឋមូលដ្ឋាន។

គណៈកម្មការសហគមន៍នេសាទមានវិធីច្រើនក្នុងការចូលរួម៖

- អញ្ជើញក្រុមប្រឹក្សាឃុំ សង្កាត់ចូលរួមក្នុងដំណើរការកសាងផែនការគ្រប់គ្រងកន្លែង នេសាទសហគមន៍
- គណៈកម្មការសហគមន៍ចូលរួមក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។
- សម្របសម្រួលសហប្រតិបត្តិការរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងសមាជិកសហគមន៍ នេសាទ

នៅមុនកិច្ចប្រជុំសមាហរណកម្មនៅថ្នាក់ក្រុងស្រុកខណ្ឌ សហគមន៍ត្រូវរៀបចំឯកសារ និងសម្ភារមួយចំនួនដើម្បីជានាកិច្ចពិភាក្សាឱ្យភាពរលូន និងបានលទ្ធផលរំពឹងទុកដូចជា៖ កម្មវិធីវិនិយោគបីឆ្នាំរំកិល (ដោយមានកិច្ចព្រមព្រៀង នៅក្នុងសមាហរណកម្មនៅថ្នាក់ក្រុងស្រុក ខណ្ឌ) ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

គោលបំណងនៃការកសាង ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដើម្បីឱ្យឃុំសង្កាត់ កៀរគរធនធានទាំងក្នុង និងក្រៅមូលដ្ឋាន និងសម្រេចអំពីការប្រើប្រាស់ធនធាននោះក្នុងការដោះស្រាយបញ្ហា និងបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋមូលដ្ឋាន។

## សារតារ

គម្រោង "ការគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ - ដំណាក់កាលទី៣" ទទួលបានមូលនិធិពីធនាគារពិភពលោក។ គោលបំណងគម្រោង គឺដើម្បីបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងធនធានទឹក និងការគ្រប់គ្រងធនធានជលផលប្រកបដោយប្រសិទ្ធភាព នៅភាគឦសាននៃប្រទេសកម្ពុជា។ សមាសភាគទី ១ (ការគ្រប់គ្រងធនធានជលផលនៅភាគឦសាននៃប្រទេសកម្ពុជា) គ្រប់គ្រងដោយរដ្ឋបាលជលផល និងអនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប។ គោលបំណងនៃសមាសភាគទី១គឺដើម្បីកែលម្អការគ្រប់គ្រងធនធានជលផលនៅក្នុងតំបន់គោលដៅដែលបានជ្រើសរើសនៅក្នុងខេត្តក្រចេះ និងស្ទឹងត្រែង។

## សៀវភៅមេរៀនចំនួន៥ ស្តីពីសហគ្រប់គ្រងធនធានជលផល

សៀវភៅមេរៀននេះគឺជាផ្នែកមួយនៃសៀវភៅមេរៀនជាស៊េរីចំនួន៥ ស្តីពីសហគ្រប់គ្រងជលផលនៅកម្ពុជា។ សៀវភៅមេរៀនទាំងនេះ សម្រាប់ភូមិដែលមានបំណងចង់បង្កើតសហគមន៍នេសាទ សមាជិកសហគមន៍នេសាទ សមាជិកគណៈកម្មការសហគមន៍នេសាទ និងមន្ត្រីខណ្ឌរដ្ឋបាលជលផល។

*សៀវភៅទី១: ការបង្កើតសហគមន៍នេសាទសហគមន៍*
*ក្រុមគោលដៅ: អ្នកភូមិ*
*សៀវភៅទី២: ការពង្រឹងសហគមន៍នេសាទ*
*ក្រុមគោលដៅ: សមាជិកសហគមន៍នេសាទ*
***សៀវភៅទី៣: ការពង្រឹងគណៈកម្មការសហគមន៍នេសាទ***
*ក្រុមគោលដៅ: សមាជិកគណៈកម្មាការសហគមន៍នេសាទ*
*សៀវភៅទី៤: ការពង្រឹងសមត្ថភាពខណ្ឌរដ្ឋបាលជលផល*
*ក្រុមគោលដៅ: បុគ្គលិករដ្ឋបាលជលផល*
*សៀវភៅទី៥: ការកសាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍*
*ក្រុមគោលដៅ: សមាជិកសហគមន៍នេសាទ*
*ជាពិសេសសមាជិកគណៈកម្មាការសហគមន៍នេសាទ*

រដ្ឋបាលជលផល
វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប
អាគារលេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ប្រទេសកម្ពុជា
គេហទំព័រ ifredi-cambodia.org

9 789924 927846